# រឿង ចៅគង្វាលពពែ



# រឿង ចៅគង្វាលពពែ

ដកស្រង់ចេញពី សៀវភៅគតិលោក ភាគ៦

គូររូបដោយ លោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត(SVA)

បោះពុម្ពឆ្នាំ២០០៤

# រឿង ចៅគង្វាលពពែ





មានចៅគង្វាលពពែម្នាក់ បានកៀងពពែទៅឱ្យស៊ីស្មៅនៅឯវាលជាប់ជាយព្រៃមួយ ឆ្ងាយពីភូមិដោយ
នាំទាំងឆ្កែរបស់ខ្លួនទៅជាមួយផង ។





លុះទៅដល់វាលស្មៅ ចៅគង្វាលពពែបានឈប់សម្រាកនៅក្រោមដើមឈើធំមួយមានម្លប់ត្រជាក់ សាខា ហើយបានដោះអាវ ដោះមួកពាក់លើមែកឈើ និងដាក់ឈើច្រត់ផ្អែកនឹងដើមឈើនោះ ។





ដោយត្រូវខ្យល់ត្រជាក់រំភើយៗ ចៅគង្វាលពពែក៏ជ្រុលដេកលង់លក់នៅក្រោមដើមឈើធំនោះទៅ ។ ឯឆ្កែស្រុកក៏ដេកលក់នៅក្បែរម្ចាស់វាដែរ ។



កាលនោះ មានឆ្កែព្រៃមួយបានដើរមកឃើញហ្វូងពពែ ។ វាក៏គិតចង់ចាប់ពពែស៊ីជាអាហារ ។





ថ្ងៃមួយ ឆ្កែព្រៃគិតថា ពួកពពែអស់នេះ ពេលឃើញអញកាលណា វាផ្អើលរត់ទៅឱ្យម្ចាស់វាជួយ តែរាល់ដង   ត្រង់ម្ចាស់វាមកជិតម្ដេចក៏វាមិនផ្អើល ។







ឆ្កែព្រៃស្រាប់តែគិតឃើញឧបាយកលមួយ ។ វាក៏សម្រេចចិត្តថាទៅយកអាវ និងមួកមកពាក់ព្រមទាំង ឈើច្រត់របស់ចៅគង្វាលពពែមកកាន់ ដើម្បីធ្វើត្រាប់តាមចៅគង្វាល ទើបចាប់ពពែទាំងនោះស៊ីបាន ។







ឆ្កែព្រៃដើរលបៗ ចូលទៅកន្លែងដែលចៅគង្វាលពពែកំពុងដេក រួចក៏យកអាវ និងមួកមកពាក់ ហើយកាន់ឈើច្រត់ដើរជើងពីរ ក្លែងខ្លួនធ្វើអាការៈដូចចៅគង្វាល ដើរសំដៅទៅកាន់ហ្វូងពពែ ។





ពពែទាំងអស់នាំគ្នាស៊ីស្មៅ និងស្លឹកឈើរៀងៗខ្លួន ពុំភិតភ័យអ្វីឡើយ ព្រោះពួកវាគិតថាជាម្ចាស់វា ។ ឆ្កែព្រៃប្រុងកៀងហ្វូងពពែឱ្យចូលទៅក្នុងព្រៃជ្រៅ តែវាយល់ថា ត្រូវស្រែកដេញឱ្យឮសូរខ្លាំងៗដូចចៅគង្វាល ទើបហ្វូងពពែដើរតាមបញ្ជាវា ។ គិតរួចហើយ វាក៏ស្រែកឡើង “ហៀយ! ហៀយ ! ”។



កាលបើស្តាប់ឮសម្លេងឆ្កែព្រៃស្រែកដេញដូច្នោះ ពួកពពែសម្គាល់បានថា មិនមែនជាម្ចាស់របស់ខ្លួន ក៏ភិតភ័យ ផ្អើលបោល ស្រែកយំកងរំពងឡើង ។







សម្លេងពពែស្រែកយំខ្លាំងៗ នោះ ធ្វើឱ្យចៅតង្វាលភ្ញាក់ពីដំណេក ក្រឡេកមើលទៅឃើញ ឆ្កែព្រៃក្លែងបន្លំខ្លួនដូច្នោះ ក៏ស្រែកបង្អៀវឆ្កែស្រុកឱ្យដេញខាំឆ្កែព្រៃរត់ចូលព្រៃបាត់ ។



ចាប់ពីពេលនោះ ហ្វូងពពែបានដើររកស៊ីនៅឯវាលស្មៅដោយក្ដីសុខសាន្ត ។

ចប់





អង្គការសន្តិស្ម័គ្រចិត្ត
Shanti Volunteer Association